# សិស្សដែលរៀនចប់សាលាវិទ្យាល័យក្នុងឆ្នាំ២០១៩
# សេចក្ដីតម្រូវរបស់ក្រសួងអប់រំឡុងប៊ីច

សិស្សទាំងអស់ដែលរៀនចប់ពីសាលាវិទ្យាល័យក្នុងក្រសួងអប់រំឡុងប៊ីច ត្រូវតែបានធ្វើឲ្យដូចតាមសេចក្ដីតម្រូវទាំងឡាយខាងក្រោមនេះ

**សេចក្ដីតម្រូវអំពីពិជគណិតៈ** សិស្សត្រូវបានរៀនជាប់ថ្នាក់គណិតដែលស្មើគ្នានឹងថ្នាក់ពិជគណិត១-២ (Algebra 1-2) ប្រសិនបើមិនបានយកថ្នាក់ Algebra 1-2 នៅក្នុងថ្នាក់ទី៧និងទី៨ទេនោះ។

**សេចក្ដីតម្រូវអំពីការអប់រំកាយៈ** សិស្សត្រូវបានតម្រូវឲ្យបន្តយកថ្នាក់អប់រំកាយបើធ្វើមិនជាប់ឲ្យបាន៥លើ៦ផ្នែកនៃតែសហាត់ប្រាណ Physical Fitness Test (PFT) ដែលសិស្សត្រូវធ្វើនៅក្នុងថ្នាក់ទី៩។ សិស្សនឹងត្រូវតម្រូវឲ្យយកថ្នាក់អប់រំកាយឲ្យបានយ៉ាងតិច២០ក្រេឌិតទើបមានលក្ខណៈស្របនឹងច្បាប់សភាលេខ៧៨និង៦០១។ សិស្សនិងបន្តធ្វើតែស PFT រហូតទាល់តែជាប់។ សូមជួបអ្នកផ្ដល់ឱវាទសាលាអំពីសំណើសុំជៀសវាងការធ្វើតាមតម្រូវការនេះ បើកូនលោកអ្នកមានសិទ្ធិ។

**សេចក្ដីតម្រូវការអំពីចំនួនក្រេឌិតៈ** បច្ចុប្បន្ននេះ <u>សិស្សរាល់គ្នាត្រូវ</u>រៀនឲ្យបាន២២០ក្រេឌិតតាមប្រព័ន្ធឆមាសពីថ្នាក់ទី៩ដល់ទី១២ទើបអាចរៀនចប់ពីវិទ្យាល័យនិងបានទទួលសញ្ញាប័ត្រ។ ក្រេឌិតទាំងនេះគឺ

| | |
|---|---|
| ១.មុខវិជ្ជាដែលត្រូវការចាំបាច់(សិស្សទាំងអស់) | ១៦០ក្រេឌិត |
| ២.មុខវិជ្ជាផ្សេងទៀតដែលសិស្សមានជំរើសតាមចំណូលចិត្ត | ៦០ក្រេឌិត |
| សរុបទៅគឺ | ២២០ក្រេឌិត |

សិស្សត្រូវរៀនឲ្យបានពិន្ទុឌី "D" ដើម្បីបានទទួលក្រេឌិតសម្រាប់ការរៀនចប់ពីសាលាវិទ្យាល័យ។ ពិន្ទុ "D" និងខ្ពស់ជាងស្មើ៥ក្រេឌិត១ឆមាស។

**មុខវិជ្ជាដែលចាំបាច់ត្រូវយកៈ** សិស្សរាល់គ្នាត្រូវបានតម្រូវឲ្យយកមុខវិជ្ជាដែលមានរាយខាងក្រោមនៅក្នុងថ្នាក់ទី៩ដល់ទី១២។

***អង់គ្លេសៈ*** រៀនឲ្យបាន៤០ក្រេឌិតក្នុងប្រព័ន្ធឆមាសនូវមុខវិជ្ជាអង់គ្លេស English 1-2, 3-4, 5-6, ហើយបើសិស្សធ្វើមិនជាប់តែស CAHSEE គឺត្រូវយកថ្នាក់ English 7-8 ឬថ្នាក់អង់គ្លេសសម្រាប់សិស្សថ្នាក់ទី១២ Senior English ឲ្យបានចំនួន១០ក្រេឌិត។

***ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រសង្គមៈ*** រៀនឲ្យបាន៣០ក្រេឌិតក្នុងប្រព័ន្ធឆមាសនូវមុខវិជ្ជាប្រវត្តិសាស្ត្រពិភពលោកទំនើប ប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក រដ្ឋាភិបាលសហរដ្ឋអាមេរិក និងសេដ្ឋកិច្ច។

***គណិតសាស្ត្រៈ*** រៀនឲ្យបាន៤០ក្រេឌិតក្នុងប្រព័ន្ធឆមាសនូវមុខវិជ្ជាគណិតសាស្ត្រ ដែលមានយ៉ាងតិច១ថ្នាក់ឬ២ថ្នាក់ដែលមានតម្លៃស្មើនិងថ្នាក់ Algebra 1-2 ប្រសិនបើមិនបានយកថ្នាក់ Algebra 1-2 នៅក្នុងថ្នាក់ទី៧និងទី៨ទេនោះ។

***ការអប់រំកាយៈ*** រៀនឲ្យបាន២០ក្រេឌិតក្នុងប្រព័ន្ធឆមាសនូវមុខវិជ្ជាអប់រំកាយក្នុងថ្នាក់ទី៩និងទី១០។

***វិទ្យាសាស្ត្រៈ*** រៀនឲ្យបាន១០ក្រេឌិតក្នុងប្រព័ន្ធឆមាសនូវមុខវិជ្ជាជីវសាស្ត្រ biological/life និង១០ក្រេឌិតនូវថ្នាក់រូបសាស្ត្រ physical /earth; ឬ២០ក្រេឌិតនូវថ្នាក់វិទ្យាសាស្ត្ររួមបញ្ចូលគ្នា។

***វិចិត្តសិល្បៈឬភាសាអង់គ្លេសៈ*** រៀនឲ្យបាន១០ក្រេឌិតក្នុងប្រព័ន្ធឆមាសនូវមុខវិជ្ជាភាសាបរទេស ឬ១ឆ្នាំនូវថ្នាក់សិល្បៈឬភ្លេងក៏បាន។

***មុខវិជ្ជាជំរើសតាមចំណូលចិត្តៈ***
រៀនឲ្យបាន៦០ក្រេឌិតក្នុងប្រព័ន្ធឆមាសនូវមុខវិជ្ជាផ្សេងៗថែមទៀត។